# សេចក្តីថ្លែងការណ៍រួមទាក់ទងទៅនឹងការបន្តទង្វើខុសច្បាប់របស់អាជ្ញាធរខេត្តឧត្តរមានជ័យមកលើបុគ្គលិករបស់អង្គការសមធម៌កម្ពុជា

យើងខ្ញុំទាំងអស់គ្នាជាក្រុមអង្គការសង្គមស៊ីវិលដូចដែលបានរាយនាមខាងក្រោមសូមថ្កោលទោសចំពោះអាជ្ញាធរខេត្តឧត្តរមានជ័យ ដែលចាប់តាំងពីខែកញ្ញា ឆ្នាំ២០១៨មក បានធ្វើការការរារាំង បំពារបំពាន និងគំរាមកំហែងដល់បុគ្គលិកសិទ្ធិមនុស្ស។ ថ្មីៗនេះបុគ្គលិករបស់អង្គការសមធមិកម្ពុជាបួនរូបបានចុះទៅធ្វើការសិក្សាស្រាវជ្រាវដល់មូលដ្ឋាន ក្នុងខេត្តឧត្តរមានជ័យទាក់ទងទៅនឹងផលប៉ះពាល់នៃការបណ្តេញចេញដោយបង្ខំ ដែលបណ្តាលមកពីគម្រោងដីសម្បទានសេដ្ឋកិច្ចសម្រាប់ការអភិវឌ្ឍន៍ចំការដំណាំអំពៅ។ ចំការអំពៅនេះ ត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុនមិត្រាផលគ្រុប (MitrPhol Group)[1] ដែលជា ក្រុមហ៊ុនផ្គត់ផ្គង់ភេសជ្ជៈកូកាកូឡាធំទីបីក្នុងពិភពលោក។[2] ទិន្នន័យដែលប្រមូលបាននឹងត្រូវផ្តល់ទៅអោយគណៈកម្មការជាតិដើម្បីសិទ្ធិមនុស្សរបស់ប្រទេសថៃ(NHRCT) ដែលជាស្ថាប័នមួយកំពុងធ្វើការស៊ើបអង្កេតទៅលើសកម្មភាពនានារបស់ក្រុមហ៊ុន មិត្រា ផលគ្រុប ក្នុងប្រទេសកម្ពុជា (ចំពោះលំអិតបន្ថែមសូមអានឧបសម្ព័ន្ធ១)។

កាលពីខែកញ្ញាអាជ្ញាធរខេត្តបានរារាំងមិនអោយបុគ្គលិក២រូប របស់អង្គការសមធមិកម្ពុជា ធ្វើកិច្ចសម្ភាសន៍នៅក្នុងភូមិបុស្ស។ ក្រុមការងារស្រាវជ្រាវត្រូវបានបញ្ជូន ទៅស្នងការ

---

[1] David Pred & Michelle Nuijen, *Bittersweet Harvest: ការវាយតម្លៃទៅលើផលប៉ះពាល់សិទ្ធិមនុស្សនៃ European Union's Everything But Arms Initiative ក្នុងប្រទេសកម្ពុជា(ភ្នំពេញ:សមធមិកម្ពុជានិងការអភិវឌ្ឍន៍អន្តរជាតិ ឆ្នាំ២០១៣)ទំព័រទី២៩-៣០ និងទំព័រ៣៥ ។*

[2] *ការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុនកូកាកូឡា:សិទ្ធិដីធ្លីនិងស្ករស ថ្ងៃទី១១វិច្ឆិកាឆ្នាំ២០១៣ អាចទាញយកបាន:*<http://assets.coca-colacompany.com/6b/65/7f0d386040fcb4872fa136f05c5c/proposal-to-oxfam-on-land-tenure-and-sugar.pdf>.

នគរបាលខេត្ត ក្នុងនោះលោកស្រីមែក ហ្វូគូសាវ៉ា(Meg Fukuzawa) ដែលជាទីប្រឹក្សាអន្តរជាតិ ត្រូវបានឃុំខ្លួននៅក្នុងស្នងការនគរបាលអស់ពេញ១យប់មុនពេល ដែលគាត់ត្រូវបានបញ្ជូនត្រឡប់មកទីក្រុងភ្នំពេញវិញដោយកងកំលាំងប្រដាប់អាវុធ ។

អាជ្ញាធរអះអាងថា ក្រុមការងារត្រូវបានបណ្តេញចេញពីមូលដ្ឋានដោយសារមូលហេតុសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេ ហើយក៏ព្រោះតែលោកស្រីមែក ហ្វូគូសាវ៉ា(Meg Fukuzawa) ពុំមានលិខិតឆ្លងដែនច្បាប់ដើមនៅជាប់និងខ្លួន។ នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៤ នគរបាលក៏បានរារាំង ក្រុមការងាររបស់អង្គការសមធមិកម្ពុជាជាថ្មីម្តងទៀត ដែលលើកនេះគឺនៅក្នុងភូមិបាក់នឹម ដោយ លោកឡុង សុគន្ធ ស្នងការរងនគរបាលខេត្តឧត្តរមានជ័យបញ្ជាអោយពួកគេចាកចេញជាបន្ទាន់។ លោកឡុង សុគន្ធបានលើកហេតុផលទាំងយល់ច្រឡំថាដោយសារតែក្រុមការងាររបស់អង្គការសមធមិកម្ពុជាមិនបានជូនដំណឹងជាមុនដល់អាជ្ញាធរមូលដ្ឋានទាក់ទងទៅនឹងការចុះសិក្សាស្រាវជ្រាវរបស់ខ្លួន ដូច្នេះ ពួកគេចាំបាច់ត្រូវសុំការអនុញ្ញាតពីលោកអភិបាលខេត្តដើម្បីបន្តការងារសម្ភាសន៍របស់ពួកគេ។[3]

ក្រុមការងារ ក៏បានបន្តការងារសម្ភាសន៍នៅការិយាល័យរបស់អង្គការដៃគូក្នុងក្រុងសំរោង។ មន្ត្រីនគរបាលបានបន្តរាំងការងារប្រមូលទិន្នន័យរបស់អង្គការសមធមិកម្ពុជាដោយព្រមានអ្នកភូមិមិនអោយធ្វើដំណើរទៅកាន់ទីប្រជុំជនក្រុង ហើយកុហកពួកគាត់ទៀតថា

---

[3] *យោងទៅលើស្នងការនគរបាលខេត្ត ម៉ែន ម៉ាលី "ពុំមែនជាច្បាប់នោះទេដែលតំរូវអោយមានលិខិតអនុញ្ញាតដើម្បីសម្ភាសន៍អ្នកភូមិប៉ុន្តែពួកគេត្រូវប្រាប់អាជ្ញាធរអោយដឹងព្រោះជាមូលដ្ឋានដែលនៅក្រោមការគ្រប់គ្រងនៃអាជ្ញាធររបស់ខ្ញុំ" សូមអាន:*AunPheap and Peter Zsombor"*ប៉ូលីសខេត្តឧត្តរមានជ័យបំបែកកិច្ចប្រជុំរវាងអង្គការសង្គមស៊ីវិលនិងប្រជាជនដែលត្រូវបានបណ្តេញចេញ" ,ខេបូឌាដេលី(១០តុលា២០១៤) អាចទាញយក:*<http://www.cambodiadaily.com/news/oddar-meanchey-police-break-up-meeting-between-ngo-evictees-69542/>.

បុគ្គលិកអង្គការសមធម៌កម្ពុជាត្រូវបានចាប់ខ្លួន ព្រមទាំងបានសួរដេញដោលអ្នកភូមិដែលបានត្រឡប់មកពីទីប្រជុំជនក្រុងនៅត្រង់ចំនុចបិទផ្លូវទៀតផង។

នៅថ្ងៃទី១១តុលា ឆ្នាំ២០១៤ នគរបាលខេត្តបានឃុំខ្លួនបណ្តោះអាសន្ន និងប្រើអំពើហិង្សាលើរាងកាយដល់បុគ្គលិកអង្គការសមធម៌កម្ពុជា១រូប ខណៈដែលរូបគាត់កំពុងជូនដំណើរអ្នកភូមិត្រឡប់ទៅផ្ទះវិញតាមរថយន្តរបស់អង្គការ។ មន្ត្រីនគរបាលបានដាក់រនាំងបិទផ្លូវក្រោមលេសថាជាចំនុចត្រួតពិនិត្យចរាចរណ៍ ហើយបុគ្គលិកអង្គការសមធម៌កម្ពុជារូបនោះក៏បានចាប់ផ្តើមថតជាវីដេអូនូវសកម្មភាពរបស់មន្ត្រីនគរបាល។ ជាការឆ្លើយតបលោកញ៉ុល វុធដែលជានាយនគរបាលចរាចរណ៍ខេត្តបានព្យាយាមរឹបអូសយកម៉ាស៊ីនថតរបស់គាត់។ ដោយបុគ្គលិកអង្គការសមធម៌កម្ពុជា មិនព្រមប្រគល់ម៉ាស៊ីនថត នាយនគរបាលចរាចររូបនោះបានដាល់ពោះរបស់គាត់។[4]

អង្គការដែលជាដៃគូររបស់អង្គការសមធម៌កម្ពុជាបាននិងកំពុងទាក់ទងជាមួយក្រសួងមហាផ្ទៃ អំពីឧប្បត្តិហេតុទាំងឡាយដែលបន្តកើតមានក្នុងខេត្តឧត្តរមានជ័យ។ ដោយយោងទៅលើក្រសួងមហាផ្ទៃ អង្គការសមធម៌កម្ពុជាពុំមានសិទ្ធិធ្វើការសិក្សាស្រាវជ្រាវក្នុងខេត្តឧត្តរមានជ័យទេ ដោយហេតុថាការចុះឈ្មោះរបស់អង្គការជាមួយក្រសួងពុំរាប់បញ្ចូលនូវសកម្មភាព ដែលទាក់ទងនឹងសម្បទានដីសេដ្ឋកិច្ចឡើយ។ "ការទាមទារ" ចំពោះអង្គការមិនមែនរដ្ឋាភិបាលដែលពុំមានការិយាល័យរបស់ខ្លួននៅខេត្តត្រូវតែសុំការអនុញ្ញាត្តពីអាជ្ញាធរដែន

[4] *នៅពេលត្រូវបានសាកសួរដោយអ្នកសារពត៌មាន លោកញ៉ុល វុធពន្យល់ថាគាត់គ្រាន់តែអនុវត្តច្បាប់ចរាចរណ៍ ហើយបុគ្គលិកអង្គការសមធម៌កម្ពុជាពុំមានសិទ្ធិថតរូបរបស់នគរបាលនោះទេ។ សូមអាន:* Mech Dara and Peter Zsombor“*ក្រុមអ្នកសិទ្ធិមនុស្សអះអាងថាការបំពារបំពានក្នុងខេត្តឧត្តរមានជ័យនៅតែបន្តកើតមាន*” , *កាសែតខេមបូឌាដេលី*(*ថ្ងៃទី១៣តុលា ២០១៤*), *អាចទាញយក*: <http://www.cambodiadaily.com/news/rights-group-claims-continued-harassment-in-oddar-meanchey-69650/>.

ដីយ៉ាងហោចណាស់១សប្តាហ៍មុននិងជួបជាមួយអ្នកភូមិនោះ គឺមិនមានចែងនៅក្នុងច្បាប់របស់ប្រទេសកម្ពុជាទេ។

ទង្វើខុសឆ្គងខាងលើនេះបណ្តាលមកពីចេតនាមួយ ដែលរារាំងនូវការប្រមូលព័ត៌មានកំឡុងពេលនៃការស៊ើបអង្កេតរបស់គណៈកម្មាការជាតិដើម្បីសិទ្ធិមនុស្ស របស់ប្រទេសថៃ។ អង្គការសមធម៌កម្ពុជាបាននិងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយសហគមន៍ ដែលរងផលប៉ះពាល់ដោយសារដំណាំអំពៅក្នុងខេត្តឧត្តរមានជ័យតាំងពីឆ្នាំ២០១២មកម្ល៉េះ។ នៅមុនបេសកកម្មស្វែងរកពត៌មាន ដែលធ្វើឡើងដោយគណៈកម្មការជាតិដើម្បីសិទ្ធិមនុស្សរបស់ប្រទេសថៃក្នុងខេត្តឧត្តរមានជ័យថ្ងៃទី១១សីហា ឆ្នាំ២០១៥[5] អង្គការសមធម៌កម្ពុជាបានធ្វើការស្រាវជ្រាវស្រដៀងគ្នាដែលពេលនោះមិនមានការរំខានពីមន្រ្តីនគរបាល ឬរដ្ឋបាលអ្វីឡើយ ។

យើងសូមធ្វើការថ្កោលទោសចំពោះការរំលោភសិទ្ធិដ៏ជាក់ស្តែង របស់អាជ្ញាធរខេត្តមកលើសិទ្ធិរបស់បុគ្គលិកសិទ្ធិមនុស្សនិងសហគមន៍ដែលរងផលប៉ះពាល់ ដែលត្រូវរួចផុតពីរាល់ហិង្សាលើរាងកាយ(ជាពិសេសនៅពេលជាប់ឃុំ) និងចំពោះការឃុំខ្លួនបណ្តោះអាសន្នដូចមានចែងក្នុងច្បាប់រដ្ឋធម្មនុញនៃព្រះរាជាណាចក្រកម្ពុជា។[6] អាជ្ញាធរខេត្តក៏បានល្មើស

---

[5] Peter Zsombor, “*ផ្នែកសិទ្ធិមនុស្សរបស់ថៃនិយាយថាអ្នកគ្រប់គ្រងដំណាំអំពៅលួចកាន់កាប់ដី*”, *កាសែតខេមបូឌាដេលី*(*ថ្ងៃទី១៤សីហា ២០១៤*), *អាចទាញយក*: <http://www.cambodiadaily.com/news/thai-human-rights-body-says-plantations-stole-land-66456/>.

[6] *រដ្ឋធម្មនុញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣មាត្រាទី៣៨(៣)“ច្បាប់ចែងថាពុំអនុញ្ញាត្តអោយមានអំពើហឹង្សាទៅលើបុគ្គលណាម្នាក់ឡើយ។ច្បាប់ត្រូវការពារអាយុជីវិតកិត្តិយសនិងសេចក្តីថ្លៃថ្នូរបស់ពលរដ្ឋ។ការផ្តន្ទាទោសការចាប់ខ្លួនឬការឃុំឃាំងនណាម្នាក់ពុំត្រូវបានអនុញ្ញាត្តឡើយលើកលែងតែការអនុវត្តន៍ស្របនិងច្បាប់។ការបង្ខិតបង្ខំទារុណកម្មលើរាងកាយឬទារុណផ្លូវចិត្តដែលជាការដាក់ទោសបន្ថែមទៅលើអ្នកជាប់ឃុំត្រូវហាមឃាត់ជាដាច់ខាត។ជនប្រព្រឹត្តនឹងត្រូវផ្តន្ទាទោសទៅតាមច្បាប់*”

ចំពោះច្បាប់រដ្ឋធម្មនុញ្ញស្តីពីសេរីភាពបំលាស់ទីភាពឯកជនរបស់ពលរដ្ឋ[7] និងសេរីភាពនៃការប្រមូលផ្តុំ[8]នៅពេលដែលពួកគេត្រូវបានហាមឃាត់ ឬចាត់ទុកថាត្រូវបានហាមឃាត់ពីការធ្វើដំណើររវាងភូមិសំរោង ភូមិបុស្ស និងភូមិបាក់នឹម និងរៀបចំនូវកិច្ចប្រជុំដ៏ស្ងប់ស្ងាត់នៅក្នុងលំនៅដ្ឋានឯកជនក្នុងភូមិបាក់នឹមនោះ។

យើងខ្ញុំសូមអំពាវនាវដល់អាជ្ញាធរមានសមត្ថកិច្ចរួមទាំងក្រសួងមហាផ្ទៃ និងតុលាការខេត្តអោយធ្វើការស៊ើបអង្កេត និងផ្តន្ទាទោសចំពោះបុគ្គលដែលបានប្រព្រឹត្តនូវទង្វើមិនគប្បីចំពោះសមាជិកសហគមន៍និងបុគ្គលិកអង្គការសមធម៌កម្ពុជា រួមមានការឆែកឆេរនិងរឹបអូសដោយគ្មានដីការ ការបំបែកនូវការជួបជុំដែលស្ងប់ស្ងាត់ ការឃុំខ្លួនបណ្តោះអាសន្ន ការគំរាមកំហែងដែលបណ្តាលអោយមានការភ័យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ព្រមទាំងអំពើហិង្សានានាដោយគ្មានមូលហេតុមកលើពលរដ្ឋ។ បរាជ័យក្នុងការអនុវត្តន៍ច្បាប់ចំពោះទង្វើអសកម្មខាងលើនឹងបណ្តាលអោយបញ្ហារ៉ាំរ៉ៃបន្តកើតមាននៅក្នុងប្រពន្ធ័យុត្តិធម៌របស់ ប្រទេសកម្ពុជាដែលរាប់ទាំងនិទន្ធភាពចំពោះអាជ្ញាធរ ព្រមទាំងកង្វះខាតតម្លាភាព និងមធ្យោបាយស្វែងរកជំនួយនៅពេលជនរងគ្រោះត្រូវការ។

សេចក្តីថ្លែងការណ៍នេះធ្វើឡើងដោយៈ អង្គការសមធម៌កម្ពុជា(EC) , [...]

## *សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងទៅកាន់៖*

---

[7] *Ibid*មាត្រាទី៤០ “*សេរីភាពពលរដ្ឋក្នុងការធ្វើដំណើរជិតឬឆ្ងាយការតាំងលំនៅដោយស្របច្បាប់គួរត្រូវបានគោរព* [...]*សិទ្ធិឯកជនរបស់បុគ្គលគួរត្រូវបានធានា។*”

[8] *Ibid*មាត្រាទី៤១“*ពលរដ្ឋខ្មែរទាំងអស់មានសិទ្ធិពេលលេញក្នុងការបញ្ចេញមតិសិទ្ធិសារពត៌មានការផ្សព្វផ្សាយជាសារធារណៈនិងការប្រមូលផ្តុំ*”

លោក អៀង វុទ្ធី, នាយកប្រតិបត្តិ
អង្គការសមធម៌កម្ពុជា (EC)
ទូរស័ព្ទ: (+855) 12 791 700
អ៊ីម៉ែល: vuthy@equitablecambodia.org

លោក អ៊ី សារ៉ុម, នាយកប្រតិបត្តិស្តីទី
សមាគមន៍ធាងត្នោត (STT)
ទូរស័ព្ទ: (+855) 89 666 036
អ៊ីម៉ែល: sarom@teangtnaut.com

លោកស្រី ចក់ សុភាព, នាយកប្រតិបត្តិ
មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(CCHR)
ទូរស័ព្ទ: (+855) 11 943 213
អ៊ីម៉ែល: chaksopheap@cchrcambodia.org

កញ្ញា ណាលី ពីឡូក, នាយិកា
សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ
ទូរស័ព្ទ: (+855) 12 803 650
អ៊ីម៉ែល: director@licadho-cambodia.org

កញ្ញា លី រ៉ូប៊ីនសុន, នាយិកា
សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ កាណាដា
ទូរស័ព្ទ: (+855) 17 799 715
អ៊ីម៉ែល: lee@licadhocanada.com

កញ្ញា ខូលេត អូរីហ្គេន, អ្នកសម្របសម្រួល
សកម្មភាពរបស់ពលរដ្ឋដើម្បីការផ្លាស់ប្តូរ(PAC)
ទូរស័ព្ទ: (+855) 17 559 150
អ៊ីម៉ែល: colletteoregan@gmail.com

លោកដេវិត ប្រេដ, នាយក
អង្គការអភិវឌ្ឍន៍ដោយមានការចូលរួមអន្តរជាតិ (IDI)
ទូរស័ព្ទ:+1 (917) 280-2705
អ៊ីម៉ែល: david@inclusivedevelopment.net

លោក សួន ប៊ុនស័ក្តិ,ប្រធានលេខាធិការដ្ឋាន
គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)
ទូរស័ព្ទ: (+855) 92 344357
អ៊ីម៉ែល:suonbunsak.chrac@yahoo.com

លោក សេង សុខហេង, អ្នកសម្របសម្រួលលេខាធិការ
បណ្តាញកសាងសន្តិភាព (CPN)
ទូរស័ព្ទ: (+855) 92 324 668
អ៊ីម៉ែល: seng.sokheng@gmail.com

លោក ថេង សាវឿន, អ្នកសម្របសម្រួល
សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)
ទូរស័ព្ទ: (+855) 12 707 381
អ៊ីម៉ែល: ccfc.cambodia@gmail.com

កញ្ញា ណេវ៉ា ធួន, នាយកប្រចាំប្រទេស

Diakonia

ទូរស័ព្ទ: (+855) 12 465 117

អ៊ីម៉ែល: neva.thiounn@diakonia.se

លោក សៅ វណ្ណសី, នាយកប្រតិបត្តិ

អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច(ICSO)

ទូរស័ព្ទ: (+855) 23 997 657

អ៊ីម៉ែល: vansey@icso.org.kh

អ្នកស្រី ព្រី ផល្លីផួង, នាយកប្រតិបត្តិ

អង្គការអភិវឌ្ឍន៍សម្លេងសហគមន៍ (BCV)

ទូរស័ព្ទ: (+855) 89 885 625

អ៊ីម៉ែល: phuongbcv@gmail.com

លោក សរ ម៉ូរ៉ា, ប្រធាន

សហព័ន្ធកម្មករសេវាកម្ម និងម្ហូបអាហារកម្ពុជា (CFSWF)

ទូរស័ព្ទ: (+855) 23 455 9991

អ៊ីម៉ែល: contact@cfswf.org

លោក មី ណាក់, អ្នកចាត់ការផ្នែក

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)

ទូរស័ព្ទ: (+855) 12 475 741

អ៊ីម៉ែល:  nac.mi@ccc-cambodia.org

លោក សៀ ភារម្យ, នាយក
ក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋាន (HRTF)
ទូរស័ព្ទ: (+855) 60 313 451
អ៊ីម៉ែល: sd@hrtfcambodia.org

លោក តាំង ស៊ុនហាវ, នាយកប្រចាំប្រទេស
ជំនួយរបស់ប្រជាជនណរវេ៉ស (NPA)
ទូរស័ព្ទ: (+855) 12 800 103
អ៊ីម៉ែល: sunhao@npaid.org

លោក តឹក វណ្ណារ៉ា នាយកប្រតិបត្ត
អង្គការវេទិការស្តីពីកម្ពុជា(NGOF)
ទូរស័ព្ទ: (+855) 23 214 429, Ext. 106
អ៊ីម៉ែល: vannara@ngoforum.org.kh

កញ្ញា សុខ បញ្ញា, នាយក
បន្ទាយស្រី(BanteaySrei)
ទូរស័ព្ទ: (+855) 23 216 922
អ៊ីម៉ែល: banteaysrei@online.com.kh

លោក ភាព សុខជា, ប្រធាន
សមាគមយុវជន ជនជាតិដើមភាគតិចកម្ពុជា
ទូរស័ព្ទ: (+855) 92 617 990
អ៊ីម៉ែល: pheapsocheaaips@gmail.com

លោក ម៉ុង វិចិត្រ, ជំនួយការនាយកប្រតិបត្តិ
សមាគមន៍ខ្មែរលើ
ទូរស័ព្ទ: (+855) 75 974182
អ៊ីម៉ែល: haratanakiri@gmail.com

លោក ណាតានីញែល ដុនអ៊ី ម៉ាកេស, នាយកប្រតិបត្តិ
សមន្ទ័អង្គការក្រៅរដ្ឋាភិបាលអាស៊ានសម្រាប់កំណែទម្រង់ដីធ្លី និងអភិវឌ្ឍជនបទ
(ANGOC)
ទូរស័ព្ទ: (+63) 23510581
អ៊ីម៉ែល: angoc@angoc.org

លោក អាលី អាល់ណាសានី, នាយកប្រចាំប្រទេស
Heinrich BöllStiftung
ទូរស័ព្ទ: (+855) 23 210 535
អ៊ីម៉ែល: ali.al-nasani@kh.boell.org

លោក លក្ខ័ ឆវន័, អ្នកគ្រប់គ្រងការអភិវឌ្ឍន៍
អង្គការពន្លឺនៃក្តីសង្ឃឹម
ទូរស័ព្ទ: (+855) 92 278 404
អ៊ីម៉ែល: pnks@online.com.kh